ELECTIONS

# តើអ្នកព្រួយបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួនរបស់អ្នកឬ?

ពលរដ្ឋខ្លះមានអារម្មណ៏ថាមិនមានសុវត្ថិភាពគ្រប់គ្រាន់ឡើយក្នុងការដាក់ព័ត៌មានលម្អិតរបស់ពួកគេផ្សព្វផ្សាយជាសាធារណៈនៅលើបញ្ជីបោះឆ្នោត ប៉ុន្តែការណ៍នេះមិនមានន័យថាពួកគេបាត់បង់សិទ្ធិបោះឆ្នោតឡើយ។

ប្រសិនបើអ្នកមានសិទ្ធិចុះឈ្មោះ ប៉ុន្តែជឿថាការដាក់ព័ត៌មានលម្អិតរបស់អ្នកកត់ត្រានៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលត្រូវបានបោះពុម្ពនោះ អាចគំរាមកំហែងដល់សុវត្ថិភាពផ្ទាល់ខ្លួនរបស់អ្នក ឬរបស់គ្រួសារអ្នកនោះ អ្នកអាចស្នើឲ្យដាក់ឈ្មោះរបស់អ្នកនៅលើបញ្ជីសម្ងាត់មិនផ្សព្វផ្សាយបាន។

ព័ត៌មានលម្អិតអំពីការចុះឈ្មោះបោះឆ្នោតរបស់អ្នកនឹងត្រូវបានរក្សាទុកបានល្អ ដោយមន្ត្រីចុះបញ្ជីអ្នកបោះឆ្នោត ហើយនឹងមិនបញ្ចេញឲ្យនរណាម្នាក់ឡើយ។

ELECTIONS


› elections.org.nz
› 0800 36 76 56




ROE47B Khmer 17/07

# ព្រួយបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួនរបស់អ្នកឬ?

ELECTIONS

# Complete this form to apply to go on the unpublished roll.

Full name:

Date of birth:

Contact phone number:

Email address

Address where you are enrolled to vote or have applied to enrol:

List any additional information provided to support your application:

Please tick one of the following:

- [ ] I am already enrolled
- [ ] I am not enrolled and I have enclosed a completed enrolment form

Signature/date:

- Complete and post to: Electoral Commission, PO Box 3220, Wellington 6140.
- Remember to attach any information that supports your application to register on the unpublished roll.
- For more information visit **elections.org.nz**

## របៀបស្នើសុំឲ្យដាក់ឈ្មោះលើបញ្ជីមិនផ្សព្វផ្សាយ។

ដើម្បីស្នើសុំឲ្យដាក់ឈ្មោះលើបញ្ជីមិនផ្សព្វផ្សាយ អ្នកត្រូវបំពេញ និងប្រគល់ត្រឡប់មកវិញនូវទម្រង់បែបបទនៅក្នុងខិតប័ណ្ណនេះ។ ប្រសិនបើអ្នកមិនទាន់ចុះឈ្មោះបោះឆ្នោតទេ អ្នកក៏នឹងត្រូវបំពេញទម្រង់បែបបទចុះឈ្មោះឆ្នោតនេះដែរ។ ដើម្បីទទួលបានទម្រង់បែបបទចុះឈ្មោះបោះឆ្នោតនេះ ឬទម្រង់បែបបទពាក្យសុំបន្ថែមណាមួយ អ្នកអាច៖

- ទាញយកទម្រង់បែបបទពីគេហទំព័រ **elections.org.nz**, ឬ
- ទូរសព្ទទៅកាន់លេខ **0800 36 76 56** ហើយយើងនឹងផ្ញើទម្រង់បែបបទនេះឲ្យអ្នកតាមប្រៃសណីយ៍។

## តើខ្ញុំត្រូវផ្តល់ព័ត៌មានគាំទ្រអ្វីខ្លះ?

អ្នកនឹងត្រូវផ្តល់ព័ត៌មានគាំទ្រដើម្បីបង្ហាញថាតើហេតុអ្វីបានជាអ្នកត្រូវការចុះឈ្មោះនៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោតមិនផ្សព្វផ្សាយនេះ។ ឧទាហរណ៍នៃប្រភេទព័ត៌មានទាំងនេះ រួមមាន៖

- លិខិតពីនិយោជករបស់អ្នក មេធាវីរបស់អ្នក បុគ្គលិកសង្គមរបស់អ្នក អ្នកតស៊ូមតិរបស់អ្នក ឬនរណាម្នាក់ដែលតំណាងឲ្យសហគមន៍ ដោយពន្យល់ថាតើហេតុអ្វីបានជាការងារ ឬស្ថានភាពផ្ទាល់ខ្លួនរបស់អ្នក ធ្វើឲ្យអ្នកមានហានិភ័យនេះ ឬ
- សំណៅចម្លងនៃការបញ្ជាឲ្យការពារ ដែលមានជាធរមាន ក្រោមច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារឆ្នាំ 1995 ឬ
- សំណៅចម្លងនៃការបញ្ជាហាមឃាត់សកម្មភាពបង្កអន្តរាយ ដែលមានជាធរមាន ក្រោមច្បាប់ស្តីពីការរើសអើងឆ្នាំ 1997 ឬ
- ព័ត៌មានពីមន្ត្រីនគរបាល ឬមន្ត្រីកែប្រែ ដែលពន្យល់ថាតើហេតុអ្វីបានជាសុវត្ថិភាពផ្ទាល់ខ្លួនរបស់អ្នក ឬរបស់គ្រួសារអ្នក អាចត្រូវបានធ្វើបុរេវិនិច្ឆ័យដោយការបោះផ្សាយឈ្មោះ និងអាសយដ្ឋានរបស់អ្នក។

## ចុះប្រសិនបើព័ត៌មានលម្អិតផ្ទាល់ខ្លួនរបស់ខ្ញុំផ្លាស់ប្តូរ?

អ្នកនឹងត្រូវផ្តល់ដំណឹងដល់យើង ប្រសិនបើព័ត៌មានលម្អិតណាមួយអំពីការចុះឈ្មោះបោះឆ្នោតរបស់អ្នក មានការផ្លាស់ប្តូរ ដូចជាឈ្មោះ ឬអាសយដ្ឋានរបស់អ្នកជាដើម។ អ្នកក៏អាចស្នើសុំត្រឡប់ទៅដាក់ឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតដែលបានបោះពុម្ពរួចផងដែរ ប្រសិនបើស្ថានភាពផ្ទាល់ខ្លួនរបស់អ្នកមានការផ្លាស់ប្តូរ។

ចូរទាក់ទងទៅកាន់មន្ត្រីអគ្រានុកូលដ្ឋាន ឬមន្ត្រីចុះឈ្មោះបោះឆ្នោត ដើម្បីធ្វើបច្ចុប្បន្នភាពព័ត៌មានលម្អិតរបស់អ្នក។ ព័ត៌មានទំនាក់ទំនងលម្អិតរបស់អ្នកទាំងនេះ អាចរកបាននៅគេហទំព័រ **elections.org.nz** ឬតាមរយៈការហៅទូរសព្ទទៅកាន់ **0800 36 76 56**។

## តើខ្ញុំបោះឆ្នោតដោយរបៀបណា នៅពេលខ្ញុំមានឈ្មោះនៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោតមិនផ្សព្វផ្សាយនេះ?

អ្នកអាចបោះឆ្នោតនៅកន្លែងបោះឆ្នោតណាមួយនៅក្នុងពេលបោះឆ្នោតសកល ឬបោះឆ្នោតជ្រើសរើសតំណាងរាស្ត្របន្ថែម។ អ្នកនឹងត្រូវការចុះឈ្មោះបោះឆ្នោតពិសេស ដោយសារព័ត៌មានលម្អិតរបស់អ្នក នឹងមិនត្រូវបានបញ្ចូលក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលបានបោះពុម្ព ដែលត្រូវបានប្រើប្រាស់ដើម្បីចេញសន្លឹកឆ្នោតនៅកន្លែងបោះឆ្នោតឡើយ។

អ្នកនឹងត្រូវការបំពេញទម្រង់បែបបទបន្ថែមមួយជាមួយនឹងសន្លឹកឆ្នោតរបស់អ្នក ដើម្បីបញ្ជាក់ក្រុមអ្នកបោះឆ្នោតដែលអ្នកបានចុះឈ្មោះបោះឆ្នោត។ អ្នកមិនចាំបាច់បំពេញព័ត៌មានអំពីអាសយដ្ឋាន ឬឈ្មោះពីមុននៅលើទម្រង់បែបបទឡើយ ប្រសិនបើអ្នកមិនចង់បំពេញនោះ។ ព័ត៌មានដែលអ្នកអាចផ្តល់ជូនកាន់តែច្រើន កម្រិតនៃការជួយយើងក្នុងការបញ្ជាក់ ភាពមានសិទ្ធិក្នុងការបោះឆ្នោតរបស់អ្នកក៏កាន់តែច្រើនដែរ។

នឹងមានមនុស្សម្នាក់នៅកន្លែងបោះឆ្នោតណែនាំអ្នកអំពីអ្វីដែលត្រូវធ្វើ និងកន្លែងដែលត្រូវទៅ។

ដើម្បីបោះឆ្នោតនៅថ្នាក់មូលដ្ឋាន អ្នកនឹងត្រូវការស្នើសុំឲ្យមន្ត្រីទទួលបន្ទុកកិច្ចការបោះឆ្នោតនៅក្រុមប្រឹក្សាមូលដ្ឋានរបស់អ្នក ផ្ញើសន្លឹកឆ្នោតឲ្យអ្នក។

ELECTIONS

Level 10, 34-42 Manners Street,
PO Box 3220, Wellington 6140.